ព្រះរាជាណាចក្រកម្ពុជា
ជាតិ សាសនា ព្រះមហាក្សត្រ

តាចនាមប្រជារាស្ត្រខ្មែរ
សាលាដំបូងខេត្តត្បូងឃ្មុំ

សាលាដំបូងខេត្តត្បូងឃ្មុំ

តុលាការព្រហ្មទណ្ឌ
ណុំរឿងព្រហ្មទណ្ឌលេខ៖ ៣៨៤
ចុះថ្ងៃទី០៨ ខែមិថុនា ឆ្នាំ២០២២

សាលក្រម
លេខ៖ ៥៣០ "ង"
ចុះថ្ងៃទី៣១ ខែសីហា ឆ្នាំ ២០២២

បានបើកសវនាការជាអសាធារណៈនៅថ្ងៃទី១៨ ខែសីហា ឆ្នាំ២០២២ និងប្រកាសសាលក្រម នៅថ្ងៃទី៣១ ខែសីហា ឆ្នាំ២០២២ មានសមាសភាពដូចខាងក្រោម៖

ចៅក្រមជំនុំជម្រះ

លោក [redacted] ចៅក្រមសាលាដំបូងខេត្តត្បូងឃ្មុំ ជាប្រធានក្រុមប្រឹក្សា
លោក [redacted] ចៅក្រមសាលាដំបូងខេត្តត្បូងឃ្មុំ ជាចៅក្រមប្រឹក្សា
លោក [redacted] ចៅក្រមសាលាដំបូងខេត្តត្បូងឃ្មុំ ជាចៅក្រមប្រឹក្សា

តំណាងអយ្យការ

លោក [redacted] ព្រះរាជអាជ្ញារងនៃអយ្យការអមសាលាដំបូងខេត្តត្បូងឃ្មុំ

ក្រឡាបញ្ជីសវនាការ

លោក [redacted] ក្រឡាបញ្ជីសាលាដំបូងខេត្តត្បូងឃ្មុំ

ដើម្បីជំនុំជម្រះលើជនជាប់ចោទ៖

-**ឈ្មោះ [redacted]ឌីណា** ភេទប្រុស កើតឆ្នាំ ២០០៥ (ពេលមានបទល្មើសអាយុ ១៧ឆ្នាំ) ជនជាតិខ្មែរ ទីកន្លែងកំណើតនៅភូ[redacted] ខេត្តកំពង់ចាម និងទីកន្លែងមុនពេលឃាត់ខ្លួនភូមិជ្រៃបិទមាស សង្កាត់សួង ក្រុងសួង ខេត្តត្បូងឃ្មុំ ឪពុកឈ្មោះ **អុល** (រស់) ម្តាយឈ្មោះ **ម៉ាប់** (ស្លាប់) ស្ថានភាពគ្រួសារ នៅលីវ ជាអនីតិជន (**ក្នុងឃុំ៖ ដីកាបង្គាប់ឲ្យឃុំខ្លួនលេខ ២៩២ ចុះថ្ងៃទី០៩ ខែមិថុនា ឆ្នាំ២០២២**។

-**ជាប់ចោទពីបទ៖ អំពើលួច** ប្រព្រឹត្តនៅភូមិសួងលិច សង្កាត់សួង ក្រុងសួង ខេត្តត្បូងឃ្មុំ កាលពីថ្ងៃទី០៧ ខែមិថុនា ឆ្នាំ២០២២ បទល្មើសព្រហ្មទណ្ឌដែលមានចែង និងបញ្ជត្តិឱ្យផ្តន្ទាទោសតាមមាត្រា ៣៥៣ និងមាត្រា ៣៥៦ នៃក្រមព្រហ្មទណ្ឌ។

-**មេធាវីការពារសិទ្ធិជនជាប់ចោទ៖** លោកស្រីមេធាវី[redacted] អាស័យដ្ឋាន ការិយាល័យប្រតិភូគណៈមេធាវី ប្រចាំសាលាដំបូងខេត្តត្បូងឃ្មុំ ជាមេធាវីការពារសិទ្ធិជនជាប់ចោទឈ្មោះ [redacted]**ឌីណា** ។

-**ដើមបណ្តឹងរដ្ឋប្បវេណី៖** ឈ្មោះ [redacted]**ធាន់** ភេទស្រី អាយុ ៣០ឆ្នាំ មានទីលំនៅភូមិកៀនរូង សង្កាត់វិហារសួង ក្រុងសួង ខេត្តត្បូងឃ្មុំ (មិនទាមទារសំណង) ។

បានឃើញ៖

-របាយការណ៍លេខ ១១/២០២២ ចុះថ្ងៃទី០៨ ខែមិថុនា ឆ្នាំ២០២២ របស់អធិការដ្ឋាននគរបាលក្រុងសួង ។

-ដីកាសន្និដ្ឋានបញ្ជូនរឿងឲ្យស៊ើបសួរលេខ ២៨៤ អយ.ឃ/២២ ចុះថ្ងៃទី០៨ ខែមិថុនា ឆ្នាំ២០២២ របស់តំណាងអយ្យការអមសាលាដំបូងខេត្តត្បូងឃ្មុំ

Scanned with CamScanner

-ដីកាសម្រេចឃុំខ្លួនបណ្តោះអាសន្នឈ្មោះ [redacted] ឌីណា លេខ ៨៨៨ ព្រ.ទ១ ចុះថ្ងៃទី០៨ ខែមិថុនា ឆ្នាំ ២០២២ របស់ចៅក្រមស៊ើបសួរ នៃសាលាដំបូងខេត្តត្បូងឃ្មុំ ។

-ដីកាសន្និដ្ឋានស្តាពរលេខ ៣១២ អយ.ឃ/២២ ចុះថ្ងៃទី១៩ ខែកក្កដា ឆ្នាំ២០២២ របស់តំណាងអយ្យការ អមសាលាដំបូងខេត្តត្បូងឃ្មុំ ។

-ដីកាដំណោះស្រាយបញ្ហានរឿងទៅជំនុំជម្រះលេខ ១០២៩ ចុះថ្ងៃទី២០ ខែកក្កដា ឆ្នាំ២០២២ របស់ ចៅក្រមស៊ើបសួរនៃសាលាដំបូងខេត្តត្បូងឃ្មុំ ។

-ដីកាសម្រេចចាត់តាំងចៅក្រមជំនុំជម្រះលេខ ៦៨២ /២០២២ ចុះថ្ងៃទី១៥ ខែមិថុនា ឆ្នាំ២០២២ របស់ ប្រធានសាលាដំបូងខេត្តត្បូងឃ្មុំ។

អង្គហេតុ

កាលពីថ្ងៃទី០៧ ខែមិថុនា ឆ្នាំ២០២២ វេលាម៉ោង០១ យប់ ជនត្រូវចោទឈ្មោះ [redacted] **ឌីណា** បានធ្វើ សកម្មភាពលួច កុំព្យូទ័រប្រភេទ DESKTOP MONITOR CASE ចំនួន ០១គ្រឿង ម៉ាស៊ីនគិតលុយចំនួន ០១គ្រឿង និងរ៉ូឡភ្លើង ចំនួន ០២ដុំ របស់ជនរងគ្រោះឈ្មោះ ជា ធារ៉ាន់ ភេទស្រី អាយុ ៣២ឆ្នាំ នៅចំណុចភូមិសួងលិច សង្កាត់ សួង ក្រុងសួង ខេត្តត្បូងឃ្មុំ ។

ឆ្លើយសារភាព

១-ជនជាប់ចោទឈ្មោះ [redacted] **ឌីណា** ឆ្លើយថា៖ ចំពោះបទចោទប្រកាន់ខាងនេះ រូបខ្លួនពិតជាបានប្រព្រឹត្តអំពើ លួចប្រាកដមែន គឺកាលពីថ្ងៃទី០៧ ខែមិថុនា ឆ្នាំ២០២២ វេលាម៉ោង០១ យប់ ខ្លួនបានធ្វើសកម្មភាពលួច កុំព្យូទ័រ ប្រភេទ DESKTOP MONITOR CASE ចំនួន ០១គ្រឿង ម៉ាស៊ីនគិតលុយចំនួន ០១គ្រឿង និងរ៉ូឡភ្លើង ចំនួន ០២ដុំ របស់ជនរងគ្រោះឈ្មោះ [redacted] ធារ៉ាន់ ។ មុនពេលដែលខ្លួនសម្រេចចិត្តលួចនេះ គឺខ្លួនបានគិតទុកមុនរយៈពេល១ខែ មកហើយ ទើបដល់ថ្ងៃកើតហេតុនេះខ្លួនបានចូលលួចតែម្តង។ ដំបូងឡើយខ្លួនបានទៅលួចវត្ថុនេះ ម្តងមួយៗយក ទៅដាក់នៅជិតសាលារៀន។ ហើយផ្ទះរបស់ជនរងគ្រោះដែលខ្លួនចូលនេះ គឺជាហាងលក់កាហ្វេ កន្លែងលេងឆ្នោត ឡូតូ និងជាកន្លែងលេងល្បែងមាន់ជល់តាមប្រពន្ធអ៊ីធ័រណែត ហើយដោយសារនៅក្នុងផ្ទះនោះពុំបានចាក់សោរនោះទេ ទើបជាហេតុសម្រេចចិត្តលួចតែម្តង នៅពេលពេលខ្លួនលួចសម្ភារៈខាងលើនេះបានហើយ ខ្លួនគិតថាយកទៅលក់ នៅផ្សារសួងដើម្បីយកប្រាក់ចាយ តែក៏ត្រូវបានសមត្ថកិច្ចមកឃាត់ខ្លួនតែម្តង។ ខ្លួនបានដឹងអំពីកំហុសហើយ សូម ឲ្យតុលាការជួយបន្ធូរបន្ថយទោសដល់រូបខ្លួន ខ្លួនសន្យាថាឈប់ប្រព្រឹត្តអំពើបែបនេះតទៅទៀតហើយ។

២-ចម្លើយសាក្សីឈ្មោះ [redacted] **សុភានី** ឆ្លើយថា៖ នៅថ្ងៃកើតហេតុនោះ ខ្លួនពុំបានដឹងអ្វីនោះទេ ទើបតែមកដល់ វេលាម៉ោង ១២ ថ្ងៃត្រង់ ក្រោយពេលថ្ងៃកើតហេតុនោះ ទើបខ្លួនបានដឹងហេតុការណ៍អំពីរឿងរ៉ាវដែលឈ្មោះ [redacted] ឌីណា បានចូលលួចសម្ភារៈដូចជា កុំព្យូទ័រប្រភេទ DESKTOP MONITOR CASE ចំនួន ០១គ្រឿង ម៉ាស៊ីនគិត លុយចំនួន ០១គ្រឿង និងរ៉ូឡភ្លើង ចំនួន ០២ដុំ ផ្ទះរបស់ឈ្មោះ [redacted] ធារ៉ាន់ នៅក្នុងហាងលក់កាហ្វេរបស់គាត់ ហើយ ខ្លួនចង់ដឹងថាមុខអ្នកលួចជាអ្នកណា ក៏បានទៅមើលឃើញមុខរបស់អ្នកលួចនោះតែម្តង ក្រៅពីនេះខ្លួនពុំដឹងអ្វីទៀត នោះទេ។

៣-អំណានចម្លើយដើមបណ្តឹងរដ្ឋប្បវេណី ឈ្មោះ [redacted] **ធារ៉ាន់** បានឆ្លើយនៅក្នុងដំណាក់កាលមន្ត្រីនគរបាល យុត្តិធម៌ថា៖ កាលពីថ្ងៃទី៣១ ខែឧសភា ឆ្នាំ២០២២ នាងខ្ញុំបានលក់ឆ្នោតឡូតូ តាមកុំព្យូទ័រជាមួយឈ្មោះ [redacted] សុភានី ភេទស្រី អាយុ ២៣ឆ្នាំ និងជាមួយឈ្មោះ [redacted] សូឡី នៅកន្លែងតូបលក់បាយនាងខ្ញុំ រហូតដល់ថ្ងៃទី០៦ ខែមិថុនា ឆ្នាំ២០២២ វេលាម៉ោងប្រហែល ២២ និង ៣០នាទីយប់ ទើបត្រឡប់មកពីបុណ្យមិត្តភ័ក្ត ហើយបានចូល ទៅគេងនោះផ្ទះខាងម្តាយក្មេករបស់បងស្រីរបស់ខ្លួន មកដល់វេលាម៉ោង ០៥ និង ០០ នាទីព្រឹក ចូលដល់ថ្ងៃទី

Scanned with CamScanner

០៧ ខែមិថុនា ឆ្នាំ២០២២ បានក្រោកមកជួយលេក់បាយ ការហ្វេឲ្យបងស្រីរបស់នាងខ្ញុំ ពេលនោះបងស្រីរបស់នាងខ្ញុំបានប្រាប់នាងខ្ញុំថា មានចោរចូលគាស់ទ្វាចូលលួចកុំព្យូទ័រមួយគ្រឿងម៉ាក DELL ម៉ាស៊ីនគិតលេខចំនួនមួយគ្រឿង និងព្រីភ្លើងសម្រាប់ដោតកុំព្យូទ័រ លុះដល់ម៉ោង ០៧ និង ០០នាទីព្រឹកម្ចាស់ផ្ទះនៅទល់មុខផ្ទះរបស់បងស្រីនាងខ្ញុំដើរមកសួរ មានបាត់របស់អត់ ពេលនោះនាងខ្ញុំបានឆ្លើយប្រាប់ថា បាត់របស់ដូចជា កុំព្យូទ័រ ម៉ាស៊ីនគិតលេខ និងរ៉ឺឡូភ្លើង ពេលនោះម្ចាស់ផ្ទះជួលក៏បានឆែកកាំមេរ៉ា បានឃើញនៅវេលាម៉ោង ១២ និង ៤៥នាទីយប់ មានមុស្សម្នាក់សម្បុរខ្មៅ សក់ក្រញាញ់ ដើរចូលរកលួចរបស់របរផ្ទះរបស់គាត់តែលួចមិនបានក៏បានចូលទៅលួចរបស់របរនៅតូបរបស់នាងខ្ញុំ ពេលឮដូច្នេះ បងថ្លៃនាងខ្ញុំក៏បានទៅប្តឹងសមត្ថកិច្ចតែម្តង លុះដល់វេលាម៉ោង ១២ និង ០០ នាទីថ្ងៃត្រង់ សមត្ថកិច្ចក៏បានចុះទៅដល់កន្លែងកើតហេតុរួច បានរកឃើញអត្តសញ្ញាណរបស់ជនសង្ស័យឈ្មោះ [redacted] ឌីណា និងបានឃាត់ខ្លួនធ្វើការសាកសួរក៏បានដឹងថា ឈ្មោះ [redacted] ឌីណា ភេទប្រុស អាយុ ១៧ ឆ្នាំពិតជាបានធ្វើសកម្មភាពលួចប្រាកដមែន។ ខ្លួនមិនទាមទារសំណងអ្វីទេ សុំឲ្យចាត់ការតាមច្បាប់ ។

៤-អំណានចម្លើយសាក្សីឈ្មោះ [redacted] **ភារ៉ា** បានឆ្លើយនៅក្នុងដំណាក់កាលមន្ត្រីនគបាលយុត្តិធម៌ថា៖ នាងខ្ញុំនិងប្តីរបស់នាងខ្ញុំឈ្មោះ [redacted] តុលា ភេទប្រុស អាយុ ៣៨ឆ្នាំ បានទិញតូបលក់ការហ្វេ លក់បាយនៅកន្លែងជាប់បេនឡានក្រុងសួង ស្ថិតនៅភូមិសួង សង្កាត់សួង ក្រុងសួង ខេត្តត្បូងឃ្មុំ រយៈពេលជាង មួយឆ្នាំមកហើយ ប្រហែលពីរខែមុន ឈ្មោះ [redacted] សូឡី ភេទប្រុស អាយុប្រហែល ៣៨ឆ្នាំ បានជួលតូបនាងខ្ញុំ ដាក់កុំព្យូទ័រ លក់ឆ្នោតឡូតូ ព្រោះមានអ្នកធឹកការហ្វេ និងអ្នកលេងច្រើន ហើយនៅថ្ងៃទី ៣១ ខែ ឧសភា ឆ្នាំ២០២២ បុគ្គលិកលក់ឆ្នោតឡូតូ ឲ្យឈ្មោះ [redacted] សូឡី ឈប់ពេលនោះប្អូនរបស់នាងខ្ញុំឈ្មោះ [redacted] ធារ៉ាន់ ភេទស្រី អាយុ៣០ឆ្នាំ និងឈ្មោះ សុភានី ភេទស្រី អាយុ ២៣ឆ្នាំ បានមកលក់ឆ្នោតជំនួសឈ្មោះ [redacted] សូឡី និងជួលលក់បាយ ការហ្វេ នាងខ្ញុំពេលពួកគាត់ទំនេរ។ រហូតមកដល់ថ្ងៃ០៦ ខែមិថុនា ឆ្នាំ២០២២ នៅវេលាម៉ោង២២ និង០០ នាទីយប់ គ្រួសាររបស់នាងខ្ញុំរៀបចំចូលគេងទាំងអស់គ្នា លុះមកដល់វេលាម៉ោង ០៤ និង ៣០នាទីឈានចូលដល់ថ្ងៃទី០៧ ខែមិថុនា ឆ្នាំ២០២២ ប្តីរបស់នាងខ្ញុំបានក្រោកដាំបាយ ឆុងការហ្វេ ពេលនោះស្រាប់តែបាត់ កុំព្យូទ័រ ម៉ាស៊ីនគិតលេខ និងរ៉ឺឡូភ្លើង ពេលនោះប្តីរបស់នាងខ្ញុំ និងនាងខ្ញុំបានដើរទៅឃើញទ្វាបានបាក់គន្លឹះ ពេលនោះ ទើបដឹងថាមានចោរចូលលួច រហូតដល់ម៉ោង ០៥ និង ០០នាទី ប្អូនស្រីនាងខ្ញុំក្រោកមកជួយលក់ នាងខ្ញុំប្រាប់វាអំពីរឿងនេះ លុះដល់វេលាម៉ោង ០៧ និង ០០នាទី ម្ចាស់ផ្ទះនៅទល់មុខផ្ទះរបស់នាងខ្ញុំដើរមកសួរ នាងខ្ញុំ និងប្អូននាងខ្ញុំថា មានបាត់របស់អត់ ពេលនោះប្អូនរបស់នាងខ្ញុំបានឆ្លើយប្រាប់ថាបាត់របស់ដូចជា កុំព្យូទ័រ ម៉ាស៊ីនគិតលេខ និងរ៉ឺឡូភ្លើង បន្ទាប់មកម្ចាស់ផ្ទះជួលនោះក៏បានឆែកកាំមេរ៉ាបានឃើញនៅវេលាម៉ោង ១២ និង ៤៥នាទីយប់ មានមនុស្សម្នាក់សម្បុរខ្មៅ សក់ក្រញាញ់ ដើរចូលរកលួចរបស់របរផ្ទះរបស់គាត់តែលួចមិនបានក៏បានចូលទៅលួចរបស់របរនៅតូបរបស់នាងខ្ញុំ ពេលឮដូច្នេះ ប្តីរបស់នាងខ្ញុំក៏បានទៅប្តឹងសមត្ថកិច្ចតែម្តង លុះដល់វេលាម៉ោង ១២ និង ០០នាទីថ្ងៃត្រង់ សមត្ថកិច្ចក៏បានចុះទៅដល់កន្លែងកើតហេតុរួចបានរកឃើញអត្តសញ្ញាណរបស់ជនសង្ស័យឈ្មោះ [redacted] ឌីណា និងបានឃាត់ខ្លួនធ្វើការសាកសួរក៏បានដឹងថា ឈ្មោះ អុល ឌីណា ភេទប្រុស អាយុ ១៧ ឆ្នាំពិតជាបានធ្វើសកម្មភាពលួចប្រាកដមែន ។

៥-តំណាងអយ្យការធ្វើសេចក្តីសន្និដ្ឋាន៖ ក្រោយពីពិភាក្សាដេញដោល ឃើញថា តាមរយៈអង្គហេតុ ភស្តុតាងមាននៅក្នុងសំណុំរឿង និងចម្លើយខាងលើ បង្ហាញឲ្យឃើញថា ពិតជាមានបទល្មើសលួច ដែលប្រព្រឹត្តដោយឈ្មោះ [redacted] **ឌីណា** ភេទប្រុស អាយុ ១៧ឆ្នាំ ជាអនីតិជន ប្រព្រឹត្តនៅភូមិសួងលិច សង្កាត់សួង ក្រុងសួង ខេត្តត្បូងឃ្មុំ កាលពីថ្ងៃទី០៧ ខែមិថុនា ឆ្នាំ២០២២ បទល្មើសព្រហ្មទណ្ឌដែលមានចែង និងបញ្ជត្តិឱ្យផ្តន្ទាទោសតាមមាត្រា ៣៥៣ និងមាត្រា ៣៥៦ នៃក្រមព្រហ្មទណ្ឌ។ ដូចនេះ រក្សាបទចោទ ដែលមាននៅក្នុងដីកាសន្និដ្ឋានស្តាពរលេខ ៣១២ អយ

Scanned with CamScanner

.ឃ/២២ ចុះថ្ងៃទ០១៩ ខែកក្កដា ឆ្នាំ២០២២ របស់តំណាងអយ្យការអមសាលាដំបូងខេត្តត្បូងឃ្មុំទុកជាបានការដដែល និងប្តឹងសុំផ្តន្ទាទោសជនជាប់ចោទទៅតាមនីតិវិធីច្បាប់។

៦-មេធាវីការពារសិទ្ធិរបស់ជនជាប់ចោទធ្វើសេចក្តីសន្និដ្ឋាន៖ ក្រោយពីពិភាក្សាដេញដោល ឃើញថា ក្រោយពីបានពិនិត្យលើឯកសារ និងភស្តុតាងនានាដែលមានក្នុងសំណុំរឿង តាមការសាកសួរនាពេលសវនាការ និងតាមចម្លើយរបស់កូនក្តីនាងខ្ញុំឈ្មោះ អុល ឌីណា បានឆ្លើយសារភាពអស់ហើយ ហើយកូនក្តីរបស់នាងខ្ញុំជាអនីតិជន ជាហេតុនាំឲ្យមានការខ្វះការយល់ដឹង ខ្វះការគិតពិចារណាមិនបានវែងឆ្ងាយ ដូច្នេះ សូមតុលាការជួយបន្លូរបន្ថយទោសដល់កូនក្តីនាងខ្ញុំផង ។

-ក្រោយពី បានស្តាប់ចម្លើយរបស់ជនជាប់ចោទ, ដើមបណ្តឹង និងសាក្សី
-ក្រោយពី បានស្តាប់សេចក្តីសន្និដ្ឋាន និងការប្តឹងសុំរបស់តំណាងអយ្យការ
-ក្រោយពី បានស្តាប់សេចក្តីសន្និដ្ឋាន របស់មេធាវីការពារសិទ្ធិជនជាប់ចោទ
-ក្រោយពី បានពិនិត្យលើឯកសារភស្តុតាងនានា
-ក្រោយពី បានពិនិត្យ និងពិភាក្សាពិចារណាត្រឹមត្រូវតាមច្បាប់ហើយ

<u>សំអាងហេតុ</u>

១/ កាលពីថ្ងៃទី០៧ ខែមិថុនា ឆ្នាំ២០២២ វេលាម៉ោង០១ យប់ ជនត្រូវចោទ**ឈ្មោះ [redacted] ឌីណា** បានធ្វើសកម្មភាពលួច កុំព្យូទ័រប្រភេទ DESKTOP MONITOR CASE ចំនួន ០១គ្រឿង ម៉ាស៊ីនគិតលុយចំនួន ០១គ្រឿង និងរ៉ូឡូភ្លើង ចំនួន ០២ដុំ របស់ជនរងគ្រោះឈ្មោះ [redacted] ធារ៉ាន់ ភេទស្រី អាយុ ៣២ឆ្នាំ នៅចំណុចភូមិសួងលិច សង្កាត់សួង ក្រុងសួង ខេត្តត្បូងឃ្មុំ ។

២/ អង្គហេតុ និងសកម្មភាពរបស់ជនជាប់ចោទ ដែលបានប្រព្រឹត្តនៅភូមិសួងលិច សង្កាត់សួង ក្រុងសួង ខេត្តត្បូងឃ្មុំ កាលពីថ្ងៃទី០៧ ខែមិថុនា ឆ្នាំ២០២២ ខាងលើនេះ គឺជាបទល្មើសព្រហ្មទណ្ឌ **អំពើលួច** បទល្មើសព្រហ្មទណ្ឌដែលមានចែង និងបញ្ញត្តិឱ្យផ្តន្ទាទោសតាមមាត្រា ៣៥៣ និងមាត្រា ៣៥៦ នៃក្រមព្រហ្មទណ្ឌ។

៣/ ជនជាប់ចោទ [redacted] **ឌីណា** ឆ្លើយថាសារភាព ចំពោះបទចោទប្រកាន់ខាងនេះ រូបខ្លួនពិតជាបានប្រព្រឹត្តអំពើលួចប្រាកដមែន គឺកាលពីថ្ងៃទី០៧ ខែមិថុនា ឆ្នាំ២០២២ វេលាម៉ោង០១ យប់ ខ្លួនបានធ្វើសកម្មភាពលួច កុំព្យូទ័រប្រភេទ DESKTOP MONITOR CASE ចំនួន ០១គ្រឿង ម៉ាស៊ីនគិតលុយចំនួន ០១គ្រឿង និងរ៉ូឡូភ្លើង ចំនួន ០២ដុំ របស់ជនរងគ្រោះឈ្មោះ [redacted] ធារ៉ាន់។ ខ្លួនបានដឹងអំពីកុំហុសហើយ សូមតុលាការជួយបន្លូរបន្ថយទោសដល់រូបខ្លួន ខ្លួនសន្យាថាឈប់ប្រព្រឹត្តអំពើបែបនេះតទៅទៀតហើយ។ ហេតុដូច្នេះ គប្បីតុលាការពិនិត្យ និងសម្រេចផ្តន្ទាទោស តាមនីតិវិធីច្បាប់ ។

៤/ យោងចម្លើយ ចម្លើយដើមបណ្តឹងរដ្ឋប្បវេណី/ជនរងគ្រោះ សាក្សី និងភស្តុតាងឯកសារផ្សេងៗក្នុងសំណុំរឿង គឺមានភាពស៊ីសង្វាក់គ្នា ដែលបង្ហាញឲ្យឃើញពី **ពិរុទ្ធភាព** របស់ជនជាប់ចោទពី <u>**បទ៖ អំពើលួច**</u> ប្រព្រឹត្តនៅភូមិសួងលិច សង្កាត់សួង ក្រុងសួង ខេត្តត្បូងឃ្មុំ កាលពីថ្ងៃទី០៧ ខែមិថុនា ឆ្នាំ២០២២ បទល្មើសព្រហ្មទណ្ឌដែលមានចែង និងបញ្ញត្តិឱ្យផ្តន្ទាទោសតាមមាត្រា ៣៥៣ និងមាត្រា ៣៥៦ នៃក្រមព្រហ្មទណ្ឌ។

៥/ ជនជាប់ចោទឈ្មោះ [redacted] **ឌីណា** នាពេលប្រព្រឹត្តបទល្មើសស្ថិតនៅក្នុងអាយុ ១៧ឆ្នាំ ជាអនីតិជន ហេតុដូច្នេះ គប្បីតុលាការ លើកយកមាត្រា១៦០ នៃក្រមព្រហ្មទណ្ឌ (មូលទោសអនុវត្តចំពោះអនីតិជនអាយុចាប់ពី១៤ឆ្នាំឡើងទៅ) មកពិនិត្យ និងសម្រេច តាមនីតិវិធីច្បាប់។

៦/ ដោយបណ្តឹងរដ្ឋប្បវេណី មិនទាមទារសំណងផ្នែករដ្ឋប្បវេណីអ្វីនោះទេ ហេតុដូច្នេះ តុលាការ មិនពិនិត្យ និងពិចារណាសម្រេច ពីសំណងរដ្ឋប្បវេណី ទេ ។

៧/ អំពើល្មើសរបស់ជនជាប់ចោទ បង្កឱ្យប៉ះពាល់ដល់សណ្តាប់ធ្នាប់ របៀបរៀបរយ និងសន្តិសុខល្អក្នុងសង្គម ហេតុដូច្នេះ តុលាការសម្រេចផ្តន្ទាទោសជនជាប់ចោទតាមច្បាប់ ។

<u>ហេតុដូច្នេះវិនិច្ឆ័យសេចក្តី</u>

- **<u>ផ្តន្ទាទោសលើជនជាប់ចោទ</u>**៖

. **ឈ្មោះ [redacted] ឌីណា** (មានសាវតារជាតិដូចខាងលើ) ជាក់ពន្ធនាគារ **ចំនួន ០៦ (ប្រាំមួយ) ខែ** ។

<u>ពីបទ</u>៖ អំពើលួច ប្រព្រឹត្តនៅភូមិសួងលិច សង្កាត់សួង ក្រុងសួង ខេត្តត្បូងឃ្មុំ កាលពីថ្ងៃទី០៧ ខែមិថុនា ឆ្នាំ២០២២ ស្របតាមមាត្រា ៣៥៣ និងមាត្រា ៣៥៦ នៃក្រមព្រហ្មទណ្ឌ។

សាលក្រមនេះ ជំនុំជម្រះ និងប្រកាសជាអសាធារណៈ ចំពោះមុខពិរុទ្ធជនឈ្មោះ [redacted] **ឌីណា** ទុកសិទ្ធិប្តឹងឧទ្ធរណ៍តាមកំណត់ច្បាប់ ៕

ថ្ងៃពុធ ៣កើត ខែ ភទ្របទ ឆ្នាំ ខាល ចត្វាស័ក ព.ស២៥៦៦
ខេត្តត្បូងឃ្មុំ ,ថ្ងៃទី ៣១ ខែ សីហា ឆ្នាំ ២០២២

<u>ក្រឡាបញ្ជីសវនាការ</u>	**<u>ចៅក្រមប្រឹក្សា</u>**	**<u>ចៅក្រមប្រឹក្សា</u>**	**<u>ប្រធានក្រុមប្រឹក្សាជំនុំជម្រះ</u>**
ហត្ថលេខា និងត្រា៖	ហត្ថលេខា៖		ហត្ថលេខាង និងត្រា៖
[redacted]	[redacted]		[redacted]

បានថតចម្លងចេញត្រឹមត្រូវពីច្បាប់ដើម។

ថ្ងៃពុធ ៥កើត ខែភទ្របទ ឆ្នាំ ខាល ចត្វាស័ក ព.ស២៥៦៦
ខេត្តត្បូងឃ្មុំ ,ថ្ងៃទី៣១ ខែ សីហា ឆ្នាំ ២០២២

បានឃើញ
<u>ប្រធានក្រុមប្រឹក្សាជំនុំជម្រះ</u>

[redacted]

<u>ក្រឡាបញ្ជី</u>

[redacted]

Scanned with CamScanner